សុន្ទរកថារបស់**ឯកឧត្តម គូម៉ាម៉ារូ យូជិ** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់
ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្ដល់ជំនួយ
សម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ របស់ប្រទេសជប៉ុន

០៦ វិច្ឆិកា ២០១៣

**សូមគោរព លោក អ៊ុម វិបុល ប្រធានមន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពង់ចាម!**
**សូមគោរព លោក កែវ វ៉យ ប្រធានមន្ទីរធនធានទឹក និងឧតុនិយមខេត្តពោធិ៍សាត់!**
**សូមគោរព អស់លោក លោកស្រី!**

ថ្ងៃនេះ ខ្ញុំមានសេចក្ដីសោមនស្សរីករាយដើម្បីចុះហត្ថលេខាលើកិច្ចសន្យាផ្ដល់ជំនួយចំនួន២ សម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ។ ខ្ញុំក៏មានសេចក្ដីសោមនស្សរីករាយយ៉ាងខ្លាំងផងដែរ ដែលកិច្ចសន្យាផ្ដល់ជំនួយទាំងនេះត្រូវបានធ្វើឡើងក្នុងឆ្នាំ២០១៣ ដែលជាឆ្នាំខួបអនុស្សាវរីយ៍ទី ៦០ នៃទំនាក់ទំនងមិត្តភាពជប៉ុន-កម្ពុជា។

គម្រោងទាំងពីរដែលយើងបានចុះហត្ថលេខានៅថ្ងៃនេះមានគោលដៅអភិវឌ្ឍវិស័យកសិកម្ម។ ដូចដែលយើងទាំងអស់គ្នាបានដឹងហើយថា វិស័យកសិកម្មគឺជាវិស័យធំជាងគេក្នុងប្រទេសដែលស្រូបយកកំលាំងពលកម្មជាង៦០%។ ដោយមូលហេតុនេះ ការអភិវឌ្ឍន៍វិស័យនេះគឺជាគន្លឹះដ៏សំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ ក៏ដូចជាការបង្កើនប្រាក់ចំណូលនៅតាមតំបន់ជនបទផងដែរ។ ជាក់ស្ដែង ការបង្កបង្កើនស្រូវគឺជាគោលដៅអាទិភាពខ្ពស់បំផុតមួយហើយរាជរដ្ឋាភិបាលបានខិតខំយ៉ាងសកម្មក្នុងការពង្រីកនិងស្ដារប្រព័ន្ធធារាសាស្ត្រនៅទូទាំងប្រទេស។

គម្រោងទីមួយមានថវិកាសរុប៩៤,៨៩១ដុល្លាអាមេរិក គឺដើម្បីពង្រីកផ្ទៃដីស្រោចស្រពក្នុងស្រុកព្រៃឈរ ខេត្តកំពង់ចាម។ គម្រោងនេះរួមមានការស្ដារទំនប់ប្រវែង៧៥០ម៉ែត្រ ជួសជុលសំណង់បញ្ចូលទឹក១កន្លែង សំណង់បញ្ចេញទឹក១កន្លែង និងសាងសង់សំណង់បញ្ចូលទឹកថ្មី១កន្លែង និងសំណង់បញ្ចេញទឹកថ្មី២កន្លែងបន្ថែមទៀត។ យើងរំពឹងថា គម្រោងនេះនឹងផ្ដល់អត្ថប្រយោជន៍ដល់ប្រជាជនប្រមាណ៣០០គ្រួសារដោយការទទួលបានទឹកស្រោចស្រពទាន់ពេលវេលា។

គម្រោងទីពីរ មានថវិកាសរុប១១០,០០៨ដុល្លាអាមេរិក គឺដើម្បីពង្រីកផ្ទៃដីស្រោចស្រពក្នុងស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ គម្រោងនេះរួមមាន ការស្ដារប្រឡាយរងប្រវែង២,៥៥០ម៉ែត្រ ជួសជុលសំណង់បញ្ចូលទឹកមួយកន្លែង សាងសង់លូប្រអប់ថ្មីមួយ សំណង់ស្ទាក់ទឹកថ្មី២កន្លែង និងសំណង់បញ្ចេញទឹកថ្មី៤កន្លែង។ យើងរំពឹងថា ប្រជាកសិករ ប្រមាណ ៥០០ គ្រួសារ នឹងទទួលបានអត្ថប្រយោជន៍ពីគម្រោងនេះ តាមរយៈការទទួលបានទឹកស្រោចស្រពទាន់ពេលវេលា។

ដោយទទួលស្គាល់អំពីសារៈសំខាន់នៃវិស័យកសិកម្មក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ចរបស់កម្ពុជា រដ្ឋាភិបាលជប៉ុនបាន និងកំពុងបន្តផ្ដល់ការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាតាមរយៈការស្ដារប្រព័ន្ធធារាសាស្ត្រ ក៏ដូចជាការផ្ទេរនូវបច្ចេកទេសធ្វើកសិកម្មជាដើម។ គម្រោងទាំងពីរនេះធ្វើឡើងតាមគោលការណ៍នៃយុទ្ធសាស្ត្រផ្ដល់ជំនួយរបស់ជប៉ុនសម្រាប់កម្ពុជា និងស្របតាមទស្សនៈនៃការផ្ដល់ជំនួយដើម្បីលើកស្ទួយសន្តិសុខមនុស្សជាតិសម្រាប់ប្រជាជនងាយរងគ្រោះផងដែរ។

ខ្ញុំសង្ឃឹមថា គម្រោងទាំងពីរនេះនឹងត្រូវបានអនុវត្តយ៉ាងរលូន និងប្រកបដោយប្រសិទ្ធភាព ព្រមទាំងថែទាំយ៉ាងត្រឹមត្រូវដើម្បីប្រជាជនកាន់តែច្រើនអាចទទួលបានអត្ថប្រយោជន៍ពីគម្រោងទាំងនេះ។

ជាចុងក្រោយនេះ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាគម្រោងនេះនឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និង ប្រជាជនកម្ពុជា។ សូមអរគុណ!